


## គោបា

### TAUREAU

មានគូស្វាមីភរិយាកសិករមួយគូដែលទៅចូលរួមក្នុងពិធីប្រគល់រង្វាន់ដល់ការប្រឡងប្រជែងគោបា។ ពិធីករប្រកាសលទ្ធផលគោបាដែលខ្លាំងជាងគេទាំងបីដែលត្រូវទទួលរង្វាន់:

ចំណាត់ថ្នាក់លេខ៣បានទៅលើគោឈ្មោះ ហេ្សដេអុងដែលមានអាយុ ៣ឆ្នាំ ហើយអាចដាក់មេបានបីដងក្នុងមួយថ្ងៃ!

ប្រពន្ធយកកែងដៃគោះប្តីហើយក៏ស្រដីថា:

ឮអត់ឯង? បីដងក្នុងមួយថ្ងៃ! ឯងគួរតែរៀនតាមវាទៅ!

ពិធីករប្រកាសលទ្ធផលជាបន្តទៅទៀត:

ចំណាត់ថ្នាក់លេខ ២បានទៅលើគោឈ្មោះហេ្សរ៉ាដែលមានអាយុ ៥ឆ្នាំ ហើយអាចដាក់មេបាន ៦ដងក្នុងមួយថ្ងៃ!

ប្រពន្ធកាន់តែរំភើបខ្លាំងថែមទៀតហើយស្រដីទៅកាន់ប្តីថា:

ឮអត់? ឮអត់???

ពិធីករបន្តទៅទៀត:

ហើយចំណាត់ថ្នាក់លេខ ១បានទៅលើគោឈ្មោះហែ្សកម៉ាំងដែលមានអាយុ ៥ឆ្នាំកន្លះ ហើយដែលអាចដាក់មេបាន ៩ដងក្នុងមួយថ្ងៃ!

ប្រពន្ធកាន់តែរំភើបខ្លាំងថែមទៀតហើយស្រែកប្រាប់ទៅប្តីថា :

ឮអត់? ឮអត់? ឮអត់????

ដោយទ្រាំមិនបានប្តីក្រោកឈររួចសួរទៅកាន់ពិធីករថា :

៩ដងក្នុងមួយថ្ងៃ តើជាមួយមេតែមួយមែនទេ?

ពិធីករក៏ឆ្លើយមកវិញថា:

អត់ទេ ជាមួយមេ៩ដែរ !!!

ប្តីបែរទៅរកប្រពន្ធ រួចក៏ស្រដីឡើងថា:

ឮអត់? !!!

គូស្វាមីភរិយាមួយគូបានទៅលេងកូនគោលនៅទីវាលកូនគោលដ៏ថ្លៃអស្ចារ្យមួយ ដែលនៅជុំវិញទីនោះសុទ្ធតែជាគេហដ្ឋានល្អៗ និងមាន-តម្លៃថ្លៃមហាសាល។ ទៅដល់ឡូទី ៣ ប្តីស្រដីទៅកាន់ប្រពន្ធថា:

## អារក្សឆ្នាំ ២០០៨

### GÉNIE 2008

អូនសំឡាញ់ ប្រយ័ត្នប្រយែងណាព្រោះថាប្រសិនណាជាបាល់កូនគោលរបស់អូនខ្ទាតទៅចំបង្អួចកញ្ចក់ធ្វើឱ្យបែកនោះយើងមិនដឹងជាត្រូវសងគេអស់ប៉ុន្មាននោះទេ។

ប្រពន្ធតម្រង់ដងកូនគោលដោយប្រុងប្រយ័ត្នរួចក៏វាយ ហើយគ្រាប់កូនគោលក៏ហោះតម្រង់ទៅផ្ទាំងកញ្ចក់ដ៏ធំមួយរបស់គេហដ្ឋានដ៏ប្រណិតដែលនៅក្បែរនោះ ដែលធ្វើឱ្យផ្ទាំងកញ្ចក់បែកជាបំណែកតូចៗខ្ទេចអស់គ្មានសល់។ ប្តីខឹងប្រពន្ធជាខ្លាំង រួចក៏គំហកឱ្យប្រពន្ធខ្លាំងៗ បន្ទាប់មកគេទាំងពីរនាក់ក៏ដើរតម្រង់ទៅរកគេហដ្ឋាននោះ រួចគោះទ្វារ។ សំឡេងមួយឆ្លើយពីក្នុងផ្ទះមកថា:

អញ្ជើញចូល។

ប្តីបើកទ្វារថ្នមៗ រួចក៏ឃើញអំបែងកញ្ចក់បែករាយពាសពេញកម្រាលឥដ្ឋ និងឃើញមានដបមួយបែកនៅកន្លៀតជញ្ជាំងផងដែរ។ បុរសសង្ហារម្នាក់ស្លៀកពាក់ស្អាតបាតកំពុងអង្គុយនៅលើកៅអីមួយនិយាយ ទៅពួកគេទាំងពីរថា:

គឺអ្នកទាំងពីរមែនទេដែលជាអ្នកធ្វើឱ្យបែកកញ្ចក់ ?

ប្តីប្រពន្ធទាំងពីរឆ្លើយតបទៅវិញទាំងរតាក់រតុបថា:

ត្រូវហើយគឺពួកយើងទាំងពីរនាក់ យើងខ្ញុំមានការសោកស្តាយណាស់ចំពោះឧបត្តិវហេតុនេះ។

បុរសសង្ហារតបថា:

អីតាមពិត អ្នកទាំងពីរបានជួយខ្ញុំទៅវិញនោះទេ។ ខ្ញុំគឺជាអារក្សមួយ ហើយខ្ញុំត្រូវបានគេឃុំក្នុងដបមួយនោះអស់រយៈកាល ១000ឆ្នាំមក ហើយ។ ដើម្បីជាសញ្ញាក្នុងការដឹងគុណចំពោះអ្នកទាំងពីរ ខ្ញុំនឹងធ្វើឱ្យ បំណងប្រាថ្នា ៣បានសម្រេចដូចក្តីបំណង តែដោយសារពួកអ្នកមាន គ្នាដល់ទៅ ២នាក់ ខ្ញុំនឹងផ្តល់ដល់អ្នកនូវបំណងប្រាថ្នាម្នាក់ ១ ហើយ នៅសល់បំណងប្រាថ្នា ១ គឺសម្រាប់រូបខ្ញុំខ្លួនឯង។ ឥឡូវតើអ្នកចង់បានអ្វី ? បុរសនោះសួរទៅកាន់ប្តី។

ប្តីឆ្លើយតបដោយក្តីរំភើបទៅវិញថា:

ខ្ញុំចង់ទទួលបានលុយចំនួន ១លានដុល្លាជារៀងរាល់ខែ។

បុរសនោះតបទៅវិញថា:

ចាត់ទុកថាបំណងប្រាថ្នានេះបានសម្រេចទៅចុះ ចាប់ពីថ្ងៃស្អែកទៅ ឯងនឹងទទួលបានប្រាក់ ១លានដុល្លាជារៀងរាល់ខែ។ ចុះនាងវិញចង់បានអ្វីដែរ ? បុរសនោះសួរទៅកាន់ប្រពន្ធវិញម្តង។

នាងខ្ញុំចង់បានបានផ្ទះមួយនៅក្នុងគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោក។

អូគឺជារឿងតូចតាចណាស់ដែលយើងអាចធ្វើឱ្យបំណងប្រាថ្នានាងមួយនេះបានសម្រេចដូចបំណងនោះ ចាប់ពីថ្ងៃស្អែកទៅនាងនឹងទទួលបានប័ណ្ណកម្មសិទ្ធផ្ទះទាំងនោះហើយ។

ចុះលោកវិញ តើលោកចង់បានអ្វីដែរ ? ប្តីប្រពន្ធមួយគូនេះសួរទៅកាន់អារក្ស។

ល្អណាស់ យើងត្រូវបានគេឃុំនៅក្នុងដបអស់រយៈកាល ១000ឆ្នាំមកហើយ ហើយក្នុងអំឡុងពេលនេះ យើងមិនដែលបានរួមរ័ក្សបន្តិចណាសោះ។ ដូច្នេះ បំណងប្រាថ្នារបស់យើងគឺគ្រាន់តែចង់រួមរ័ក្សជាមួយប្រពន្ធរបស់ឯងតែប៉ុណ្ណោះនាពេលនេះ។

ប្តីប្រពន្ធសម្លឹងមុខគ្នា រួចចុងបញ្ចប់ប្តីក៏ស្រដីឡើងថា:

អីប្តូរជាមួយលុយ ១លានដុល្លារជារៀងរាល់ខែ ព្រមទាំងគេហដ្ឋានដែលនៅក្នុងគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកយើងនេះ បងជឿថាយើងអាចលើកលែងបានក្នុងរឿងមួយនេះ មែនទេ ? អូនយល់យ៉ាងណាដែរ ?

អូនយល់ស្របតាមបង។

ចប់សម្ដីនេះភ្លាម អារក្សក៏នាំប្រពន្ធបុរសនោះចូលទៅក្នុងបន្ទប់ដេក រួចគេទាំងពីរនាក់ក៏ធ្វើអ្វីៗទៅតាមសាច់រឿងរបស់គេអស់រយៈពេល ២ម៉ោង ហើយចុងបញ្ចប់បុរសនោះក៏សួរទៅកាន់នាងនោះថា:

និយាយអញ្ចឹង ប្ដីនាងមានអាយុប៉ុន្មានដែរ ?

ប្រពន្ធក៏តបទៅវិញថា:ប្ដីខ្ញុំមានអាយុ ៤០ឆ្នាំហើយ ចុះម៉េចបានជាសួរបែបនេះ ?

បុរសនោះក៏តបទៅវិញថា : ព្រោះថាមើលទៅដូចជាមិនគួរឱ្យជឿទាល់តែសោះថាអាយុ៤០ឆ្នាំហើយ នៅតែភ្លើជឿរឿងអារក្សទេវត្តាស្អីនោះទៀត។

## ឋានសួគ ឬឋាននរក

## PARADIS OU ENFER

ជាអកុសល ប៊ីល ហ្គេតបានបាត់បង់ជីវិតនាថ្ងៃមួយ ហើយក៏បានធ្វើដំណើរទៅកាន់ទីស្ថានដែលព្រលឹងត្រូវទទួលបញ្ជាឱ្យទៅនៅស្ថានណាដើម្បីទទួលនូវអំពើដែលខ្លួនបានសាង។ ពេលទៅដល់ទីស្ថាននោះ ទេវតាហ្សង់ជាអ្នកទទួលគាត់ដោយខ្លាចចិត្ត ហើយទេវតាក៏ពោលទៅកាន់ ប៊ីល ហ្គេតថា: ប៊ីល លោកធ្លាប់បានបោកប្រាស់គេមិនតិចទេ តែលោកក៏ជាមនុស្សម្នាក់ដែលប្រព្រឹត្តខ្លួនបានល្អណាស់ដែរកាលដែលលោកនៅមានជីវិតជាមនុស្សនោះ។ ឥឡូវ យើងផ្ដល់ឱកាសដល់លោកក្នុងការជ្រើសរើសទីស្ថានសម្រាប់លោក គឺរវាងឋានសួគ៌ និងឋាននរក។

ប៊ីលមានក្ដីរីករាយជាខ្លាំង ក៏ស្នើសុំថាមុននឹងធ្វើការសម្រេចចិត្ត គាត់ចង់មើលទីស្ថានទាំងពីរនោះជាមុនសិន។ គាត់ក៏ចាប់ផ្ដើមមើលឋានសួគ៌ជាដំបូងគេ : នៅឋានមួយនេះ គាត់ឃើញមានជនានុជនសោយសុខដោយសេចក្ដីស្ងប់ស្ងាត់ ស្មោះត្រង់ សាមគ្គីគ្នាហើយរស់នៅក្នុងទេសភាពដ៏ស្រស់ត្រកាលគ្មានអ្វីប្រៀបបាន។

នៅឯឋាននរកឯណោះវិញ គាត់ឃើញមានជនឆបោកជាច្រើន ស្ត្រីស្លៀកពាក់តែមួយកំណាត់លើ ឬក្រោម និយាយរួមជាទីកន្លែងអបាយមុខមួយ។ បានឃើញអ្វីទាំងនោះហើយ គាត់ក៏ត្រឡប់មកជួបទេវតាហ្សង់វិញរួចក៏ពន្យល់ទៅទេវតាថា អស់ប៉ុន្មានក៏អស់ចុះ គាត់ចង់ទៅនៅឋាននរក។ ពេលដែលគាត់ទៅដល់ទ្វារនរក យមរាជក៏បើកទ្វារទទួលគាត់ដោយផ្ទាល់ដៃ ហើយក៏អញ្ជើញគាត់ឱ្យចូលទៅក្នុងទីនោះ។ តែអ្វីដែលគាត់បានឃើញផ្ទាល់នឹងភ្នែកសឹងតែធ្វើឱ្យគាត់ដាច់ផ្ងាទៅក្រោយ ក៏ព្រោះតែវាជាឋានមួយដែលគួរឱ្យតក់ស្លុត ដែលមានអណ្ដាតភ្លើង ព្រមទាំងពួកព្រាយបិសាចកំពុងតែធ្វើទារុណកម្មអ្នកទោស...

ប៊ីលស្រង៉ាកចិត្តរួចក៏សុំការពន្យល់ពីយមរាជ:

រូបភាពទាំងនេះ អត់មានដូចគ្នាទៅនឹងរូបភាពដែលខ្ញុំបានឃើញអម្បាញ់មិញនោះទេ !!!

យមរាជក៏តបដោយទន់ភ្លន់ទៅវិញថា: យើងដឹង ឥឡូវឯងស្គាល់ពីបញ្ហាជាមួយនឹងកម្មវិធីសាកល្បងនានារបស់ឯងដែរហើយមែនទេ?

ប្រែសម្រួលពី www.blague.info ដោយ សំអោ អង្គារតន៍

## Le carnet pratique

Association des professeurs de français du Cambodge (APFC)
Siège : boulevard de la fédération de la Russie, Quartier Tuol Kork, Phnom Penh, Cambodge

- S.E. M. NEANG Muth, Président
Fax. : (855-23) 217 250 ; Tél. : 012 899 783 ; E-mail : neangmuth@yahoo.fr
- M. MAO Bunneang, Vice-Président
Tél. : 012 844 336 ; E-mail : bunneang.mao@gmail.com
- M. NY Ratha, Secrétaire Général
Tél. : 012 847 843 ; E-mail : rathany.ine@gmail.com
- M. SIENG Phen, Trésorier
Tél. : 012 980 027 ; E-mail : sieangphen@itc.edu.kh
- Mme SENG Kimha, Comptable
Tél. : 012 778 832 ; E-mail : sengkimha2006@yahoo.fr

## Sites Internet utiles

- Ministère de l'Education, de la Jeunesse et des Sports : www.moeys.gov.kh

Etablissements de l'enseignement supérieur public

- Institut National de l'Education : www.ine.edu.kh
- Institut de Technologie du Cambodge : www.itc.edu.kh
- Université Royale de Phnom Penh : www.rupp.edu.kh
- Université Royale de Droit et des Sciences Economiques : www.rule.edu.kh
- Université Nationale de la Gestion : www.num.edu.kh
- Université de Svay Rieng : www.sru.edu.kh
- Université Royale d'Agriculture : www.rua.edu.kh

## Sites francophones

- Association des professeurs de français du Cambodge : www.ine.edu.kh/apfc
- Agence universitaire de la Francophonie (A.U.F) : www.auf.org
- Agence universitaire de la Francophonie (A.U.F) Antenne du Cambodge : www.kh.refer.org
- Valorisation du français en Asie du Sud-est (VAL-OFRASE) : www.valofrase.org
- Ambassade de France au Cambodge : www.ambafrance-kh.org
- Le réseau des étudiants et stagiaires cambodgiens en France : www.francecambodge.org

- Le moteur de recherches : www.google.fr